# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

**សារលិខិតជូនពរ**

**សូមគោរពជូន**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ក្នុងឱកាសនៃការចម្រើនជន្មាយុគម្រប់៤៦ ឈានចូល ៤៧ឆ្នាំ**

**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

នាឱកាសដ៏ប្រពៃថ្លៃថ្លា និងឧត្តុង្គឧត្តមនៃការចម្រើនជន្មាយុគម្រប់៤៦ ឈានចូល ៤៧ឆ្នាំ របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ និងខ្លួនខ្ញុំផ្ទាល់ ព្រមទាំងក្រុមគ្រួសារ សូមចូលរួមសម្តែងមនោសញ្ចេតនាប្រកបដោយក្តីគោរពស្រឡាញ់ និងសោមនស្សរីករាយ ជូនចំពោះ **សម្តេចមហាបវរធិបតី** សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន ប្រាជ្ញាវាងវៃ និងជន្មាយុយឺនយូរ។

នាឱកាសដ៏សោមនស្សរីករាយនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ដោយស្មោះអស់ពីដួងចិត្ត និងគោរពដឹងគុណប្រកបដោយកក្តីកាពចំពោះ **សម្តេចមហាបវរធិបតី** ដែលបានខិតខំប្រឹងប្រែងយកអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីដើម្បីបម្រើប្រទេសជាតិ ក្នុងឧត្តមប្រយោជន៍សម្រាប់ជាតិ សាសនា ព្រះមហាក្សត្រ និងប្រជាជនកម្ពុជាឱ្យបានកាន់តែល្អប្រសើរប្រកបដោយសុកមង្គល ភាតរភាព សាមគ្គីភាព ហើយបានបង្គលក្ខណៈធ្វើឱ្យកម្ពុជាបន្តការអភិវឌ្ឍឆ្ពោះទៅមុខប្រកបដោយកិត្យានុភាពជាតិទាំងក្នុងតំបន់ និងអន្តរជាតិ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យតេជះបារមី និងទេពតារក្សាព្រះរាជាណាចក្រកម្ពុជា តាមជួយទ្រទ្រង់បីបាច់ថែរក្សា ប្រសិទ្ធពរជ័យសព្វសាធុការ ជូន **សម្តេចមហាបវរធិបតី** និង **លោកជំទាវបណ្ឌិត** ព្រមទាំង បុត្រា បុត្រីជាទីស្រឡាញ់ សូមមានសុខភាពល្អបរិបូរណ៍ សិរីមង្គល វិបុលសុខ មហាប្រសើរ គ្រប់ប្រការ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ដើម្បីបន្តដឹកនាំ អភិវឌ្ឍព្រះរាជាណាចក្រកម្ពុជាក្នុងបរិយាកាសសុខសន្តិភាពដ៏រឹងមាំ និងយូរអង្វែងតរៀងទៅ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ៦កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហ៊ុន_ម៉ានី**